# ព្រះរាជាណាចក្រកម្ពុជា

# រណសិរ្សរួបរួមជាតិកម្ពុជា

# កម្ពុជា ឆ្នាំ ១៩៧២

ដោយ លោក អៀង សារី

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Jul-2011, 10:28
CMS/CFO: Phok Chanthan

# រាជាណាចក្រកម្ពុជា

# រណសិរ្សរួបរួមជាតិកម្ពុជា

# កម្ពុជា ឆ្នាំ ១៩៧២

**ដោយ លោក អៀង សារី**

បោះពុម្ពដោយរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា

**(*រូបភាព*)៖ សេចក្តីប្រកាសជាផ្លូវការរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ចេញផ្សាយកាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៩៧១ បានជូនដំណឹងអំពីការមកដល់ក្រុងប៉េកាំងរបស់លោក អៀង សារី បេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាក្នុងប្រទេស។ នៅទីនេះ លោក អៀង សារី បាននាំនាំនូវគារវកិច្ចដ៏កក់ក្តៅពីប្រជាជនកម្ពុជាថ្វាយដល់សម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ និងជាព្រះប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជូនចំពោះសម្តេច ប៉ែន នុត ប្រធានគណៈកម្មាធិការការិយាល័យមជ្ឈឹមបក្សនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។**

.... ឥឡូវពេលនេះ ពួកគេបានផ្តល់ដល់បរិវាររបស់ខ្លួនគឺក្រុមក្បត់ជាតិ លន់ នល់ សិរិមតៈ សឺន ង៉ុកថាញ់ នូវជំនួយខាងយោធា សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានតម្លៃសរុបជាង ៣៥០លានដុល្លារសម្រាប់ដំណើរការប្រតិបត្តិការ "សន្តិភាវូបនីយកម្ម" ដែលនៅក្នុងអំឡុងពេលនោះពួកគេបានដុតចោលទាំងអស់ បំផ្លាញចោលអស់ខ្ទេចខ្ទី ចាប់អ្នកស្រុកឃុំឃាំងនៅក្នុង "ភូមិយុទ្ធសាស្ត្រ" និងបង្ខំឲ្យពួកគាត់ចូលបម្រើនៅក្នុងកងទ័ពអាយ៉ងទៀត។ ពួកគេក៏បានព្យាយាមរារាំងនិងកាត់ផ្តាច់ខ្សែបណ្តាញទំនាក់ទំនងដែលតភ្ជាប់រវាងតំបន់រំដោះខាងបូព៌ានិងខាងបស្ចិម និងរវាងខាងឧត្តរនិងខាងទក្សិណរបស់យើងផងដែរ។

ប៉ុន្តែ ផែនការឧក្រិដ្ឋទាំងនេះបានទទួលបរាជ័យយ៉ាងជូរចត់។ ដោយមានការលើកទឹកចិត្តពីសំណាក់ជ័យជំនះទាំងឡាយរបស់ពួកគាត់កាលពីពេលកន្លងមក ប្រជាជននិងកងកម្លាំងប្រដាប់អាវុធរបស់យើង នៅក្នុងរដូវវស្សាកន្លងទៅ បានធ្វើការវាយបកយ៉ាងចាស់ដៃទៅលើសត្រូវនៅក្នុងប្រតិបត្តិការ "ចេនឡា ២"។ សមរភូមិនៅរំលួង (Rum Luong) គឺជាសមិទ្ធផលខាងយោធាដ៏ធំបំផុតមួយក្នុងប្រវត្តិសាស្ត្ររបស់យើង។ បន្ទាប់មកទៀត កងកម្លាំងប្រដាប់អាវុធរំដោះប្រជាជនយើងបានបន្តសម្រុកវាយប្រហារ ដោយឥតមានបន្ធូរបន្ថយទៅលើទីតាំងរបស់ខ្មាំងនៅគ្រប់ទិសទី ជាពិសេសនៅបរិវេណជុំវិញក្រុងភ្នំពេញ (ប្រហែលជាជាង ១០គីឡូម៉ែត្រពីរដ្ឋធានីនេះ)។ ភ្នំពេញដែលឥឡូវកំពុងស្ថិតក្នុងសភាពអសន្តិសុខនោះ ត្រូវបានកាត់ផ្តាច់ពីពិភពលោកខាងក្រៅហើយ។ ពួកជនក្បត់ជាតិកំពុងតែបម្រះខ្ញើកៗយ៉ាងវឹកវរ នៅក្នុងទីក្រុងដូចត្រីកំពុងជាប់មងអញ្ចឹងដែរ។ នៅក្នុងការប៉ុនប៉ងជួយសង្គ្រោះពួកគេ កាលពីថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ១៩៧១ កងទ័ពក្រុងសៃហ្គុង

(Saigon) ចំនួន ៥០.០០០នាក់ ក្រោមបញ្ជារបស់ពួកចក្រពត្តិនិយមអាមេរិក បានធ្វើការលុកលុយចូលមកក្នុងប្រទេសកម្ពុជាជាថ្មីម្តងទៀត ពីភាគខាងកើតនិងភាគអាគ្នេយ៍ ពីផ្លូវជាតិលេខ ១៣ ទៅស្នួល ឆ្លងកាត់តាមផ្លូវជាតិលេខ ២២ ទៅក្រែក និងឆ្លងកាត់តាមផ្លូវជាតិលេខ ១ និងទន្លេមេគង្គ។ ទោះបីជាយ៉ាងណាក្តី ដំណើរផ្សងព្រេងខាងយោធាថ្មីនោះ ក៏ត្រូវបានធ្វើឲ្យខកចិត្តម្តងទៀតដែរ។ ដំណើរបាក់ទឹកចិត្តរបស់កងទ័ពក្រុងភ្នំពេញនៅតាមផ្លូវជាតិលេខ ៦ ក៏បានបណ្តាលឲ្យមានការបែកបាក់គ្នានិងភាពច្របូកច្របល់ក្នុងចំណោមមន្ត្រីជាន់ខ្ពស់ នៅក្នុងក្រុមដែលកំពុងដឹកនាំប្រទេសនេះដែរ។ ស្ថានភាពយោធាបែបនេះបានបណ្តាលឲ្យមានផលប៉ះពាល់ផ្នែកនយោបាយយ៉ាងខ្លាំង។ ពួកមេដឹកនាំយោធាដែលកំពុងត្រួតត្រានៅក្រុងភ្នំពេញ និងចៅហ្វាយអាមេរិកកាំងរបស់ពួកគេ ត្រូវបានរុញច្រានឲ្យធ្លាក់ចូលក្នុងស្ថានភាពទាល់ច្រកយ៉ាងខ្លាំង។ ការខ្វែងគំនិតគ្នារវាងក្រុមផ្សេងៗក៏កាន់តែខ្លាំងឡើងៗរហូតធ្វើឲ្យពួកជនក្បត់ជាតិទាំងនោះ ត្រូវបង្ខំចិត្តរំលាយសភាអាយ៉ងដែលជាសំបកលទ្ធិប្រជាធិបតេយ្យរបស់ពួកគេនោះចោលទាំងពីរ ដើម្បីប្រកាសអំពើផ្តាច់ការហ្វាស៊ីសនិយមរបស់ពួកគេ។ ទោះបីយ៉ាងណាក្តី តាមបញ្ជារបស់ក្រុងវ៉ាស៊ីងតុន ពួកមេដឹកនាំរបស់ក្រុងភ្នំពេញនៅតែព្យាយាមបន្តបំណងបោកបញ្ឆោតមតិសាធារណៈដោយប្រើឆាកល្ខោននៃ "ការបោះឆ្នោត" និង "ធម្មនុញ្ញក្លែងក្លាយ" ទៀត។

ប្រជាជនគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម រួមទាំងយុវជននិងបព្វជិតព្រះពុទ្ធសាសនានៅក្រុងភ្នំពេញ (ដែលមានប្រជាពលរដ្ឋកើនឡើងពី ៦០០.០០០នាក់រហូតដល់ ១.៥០០.០០០នាក់) ផងដែរ ទោះបីជាត្រូវប្រឈមនឹងវិធានការហ្វាស៊ីសយ៉ាងណាក៏ដោយ បានបង្ហាញការមិនពេញចិត្តនិងការចងកំហឹងរបស់ខ្លួនជាចំហរ ខណៈពេលដែលពួកគេជួបប្រទះការលំបាកកាន់តែខ្លាំងឡើងៗនៅក្នុងជីវិតប្រចាំថ្ងៃ ដោយបាត់បង់សេរីភាពទាំងស្រុងព្រមទាំងមានការខ្វះខាតយ៉ាងខ្លាំងនូវតម្រូវការចាំបាច់ប្រចាំថ្ងៃ (អំបិល អង្ករ ស្ករ ...)។ តម្លៃទំនិញលើទីផ្សារបានកើនឡើង ១០ដង។ ប្រាក់រៀលស្ទើរតែក្លាយជាក្រដាសសម្រាម និងឱនភាពថវិកាត្រូវបានគេប៉ាន់ប្រមាណថាយ៉ាងហោចណាស់ស្មើរនឹង ៩ពាន់លានរៀល ឬ៥០ភាគរយនៃថវិកាជាតិទាំងមូល។ ជីវិតរបស់របបនេះពឹងផ្អែកទាំងស្រុងទៅលើជំនួយខាងយោធា សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលផ្តល់ដោយរដ្ឋាភិបាលលោកនិកសុន (Nixon)។ នៅតាមតំបន់ជនបទវិញ គម្រោង "អភិវឌ្ឍន៍សហគមន៍" បានធ្លាក់ចូលក្នុង

ស្ថានភាពវិនាសអន្តរាយទាំងស្រុង។ គ្រប់ទីកន្លែងនៅក្នុងតំបន់ដែលខ្មាំងកំពុងកាន់ជាបណ្ដោះអាសន្នទាំងឡាយ អ្នកស្រុកបាននិងកំពុងតែក្រោកឈរប្រឆាំងជាមួយក្រុមជនក្បត់ជាតិដោយគ្រប់មធ្យោបាយទាំងអស់ដែលពួកគាត់អាចធ្វើទៅបាន។

**សំណួរទី ២៖ ចលនាតស៊ូរបស់ប្រជាជនកម្ពុជាបានធ្វើឱ្យពិភពលោកភ្ញាក់ផ្អើលដោយសារតែភាពរីកចម្រើនយ៉ាងលឿនរបស់ខ្លួន ប៉ុន្តែរបាយការណ៍ចេញពីតំបន់រំដោះនៅតែមានតិចតួច។ សូមលោកជួយផ្ដល់ដល់អ្នកអានរបស់យើងនូវព័ត៌មានអំពីការរីកចម្រើន ដូចជាដំបូងអំពីកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ការរៀបចំកងកម្លាំង អាវុធយុទ្ធភ័ណ្ឌ និងកលយុទ្ធរបស់ពួកគេ។**

ចម្លើយ៖ អស់រយៈពេលជាច្រើនឆ្នាំ យើងបានស្មានទុកជាមុនថាមានរដ្ឋប្រហារថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧០ ព្រោះថាយើងបានដឹងអំពីគោលបំណងរបស់ពួកចក្រពត្តិនិយមអាមេរិក។ និយាយពីកិច្ចការនយោបាយ យុទ្ធជននិងប្រជាជនយើងបានត្រៀមខ្លួនរួចជាស្រេចដើម្បីតបតទៅវិញភ្លាមៗ។ យើងមានមូលដ្ឋានសមស្របដើម្បីបើកប្រតិបត្តិការប្រយុទ្ធរបស់យើង។

កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាយើងត្រូវបានកសាង និងអភិវឌ្ឍយ៉ាងលឿនគ្រប់ផ្នែកទាំងអស់៖ ទាំងបរិមាណ កម្លាំង គុណភាព ស្មារតី ព្រមទាំងកលយុទ្ធ និងប្រសិទ្ធភាពក្នុងការប្រយុទ្ធ។ ក្រុមឧទ្ទាមប្រដាប់អាវុធទាំងបីប្រភេទ ទាហានថ្នាក់តំបន់ និងកងកម្លាំងប្រចាំការ សុទ្ធតែស្ថិតក្រោមអគ្គបញ្ជាការដ្ឋានរបស់គណៈកម្មាធិការយោធាជាតិមួយដែលមានការជួយឧបត្ថម្ភគាំទ្រពីសេនាធិការដ្ឋានមួយ។

*(រូបភាព)៖* **លោក អៀង សារី ឈរ។ រូបអង្គុយខាងឆ្វេង លោក នួន ជា អនុមេបញ្ជាការដ្ឋានជាន់ខ្ពស់យោធានៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា និងជាប្រធានផ្នែកកិច្ចការនយោបាយកងទ័ពជើងគោក។ ខាងស្ដាំ រូបអង្គុយ លោក សាឡុត ស អនុមេបញ្ជាការដ្ឋានជាន់ខ្ពស់យោធានៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា និងជាប្រធានផ្នែកកិច្ចការយោធាកងទ័ពជើងគោក។ រូបឈរខាងឆ្វេង លោក កុយ ធួន អនុរដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។**

ទាហានថ្នាក់តំបន់ឥឡូវនេះត្រូវបានរៀបចំជាកម្រិតកងវរសេនាតូច ហើយកងទ័ពប្រចាំការត្រូវបានរៀបចំជាកម្រិតកងវរសេនាធំ។ ពួកគេត្រូវបានបំពាក់ទៅដោយអាវុធយុទ្ធភ័ណ្ឌគ្រប់ប្រភេទ និងមានការយល់ដឹងខាងផ្នែកនយោបាយខ្ពស់ព្រមទាំងការប្ដេជ្ញាចិត្តយ៉ាងមុតមាំក្នុងការរុញច្រានពួកឈ្លានពានចក្រពត្តិនិយមអាមេរិក និងបរិវាររបស់ពួកគេទាំងអស់ចេញពីកម្ពុជានិងបោសសម្អាតក្រុមជនក្បត់ជាតិនៅក្នុងក្រុងភ្នំពេញដែលដឹកនាំដោយ លន់ នល់ សិរិមតៈ និងសឺន ង៉ុកថាញ់ ឱ្យអស់។ យុទ្ធជនទាំងអស់សុទ្ធតែរស់នៅជាមួយប្រជាពលរដ្ឋ មានទំនាក់ទំនងជិតស្និទ្ធជាមួយពួកគាត់ ចូលចិត្តពួកគាត់ និងបម្រើពួកគាត់អស់ពីចិត្តថ្លើម។

*(រូបភាព)*៖ **លោក សុន សេន នាយអគ្គសេនាធិការនៃកងទ័ពជាតិរំដោះប្រជាជនកម្ពុជា ជាមួយសហការីរបស់លោក។**

វិធីសាស្ត្រប្រយុទ្ធរបស់ពួកគេគឺពឹងផ្អែកទៅលើប្រតិបត្តិការវាយឆ្មក់ ដែលធ្វើឡើងដោយការចល័តទ័ពយ៉ាងលឿននិងស្ទាត់ជំនាញ និងដោយប្រើអង្គភាពវាយឆ្មក់ស្វាត់ៗដើម្បីបំបែកកម្លាំងរបស់ខ្មាំងរួចហើយបន្តវាយប្រហារពួកគេរហូតឥតឈប់ឈរ ដើម្បីកុំឱ្យពួកគេមានពេលរៀបចំកងកម្លាំង និងបង្កើន ឬស្ដារកម្លាំងចិត្តនិងកម្លាំងកាយឡើងវិញបាន។ កងកម្ម៉ង់ដូពិសេស បានបើកការវាយឆ្មក់ដូចផ្លេកបន្ទោរដើម្បីកម្ទេចខ្មាំង កងកម្ម៉ង់ដូនេះអន្ទះសារចង់យកឈ្នះលើខ្មាំងទាំងខាងកម្លាំងទ័ពនិងសម្ភារៈសឹក។ ការកម្ទេចមូលដ្ឋានអាកាសពោធិ៍ចិនតុងគឺជាឧទាហរណ៍ជាក់ស្ដែងមួយនៃស្មារតីនេះ។ នៅក្នុងប្រតិបត្តិការវាយឆ្មក់ដ៏រហ័សនិងអង់អាចក្លាហានទាំងនេះ កត្តាសំខាន់ចុងក្រោយនៃជ័យជំនះ ដូចដែលយើងធ្លាប់មានបទពិសោធន៍រួចមកហើយនោះ គឺកត្តាមនុស្ស ហើយអាវុធដ៏សំខាន់នោះគឺសម្បជញ្ញៈនយោបាយខ្ពស់ ដែលជាកត្តាធ្វើឱ្យពួកគេស្គាល់ច្បាស់អំពីធាតុពិតរបស់ខ្មាំងនិងស្គាល់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្មាំង។

**សំណួរទី ៣ និង ៤៖ ទាក់ទិននឹងបញ្ហាពួកកសិករវិញ តើលោកធ្លាប់បានអនុវត្តកំណែទម្រង់តាមបែបប្រជាធិបតេយ្យដែរឬទេ ជាពិសេសទាក់ទងនឹងបញ្ហាដីធ្លី ?**

**-តើផលិតកម្មកសិកម្មត្រូវបានរៀបចំយ៉ាងដូចម្ដេចដែរ?**

ចម្លើយ៖ កសិកម្មគឺជាបញ្ហាដែលមានសារៈសំខាន់ដ៏លើសលុប។ យើងបានចាត់វិធានការតាមបែបប្រជាធិបតេយ្យជាច្រើន ដើម្បីចលនាកសិករក្រីក្រ ដែលជាកម្លាំងដ៏សំខាន់នៃសង្គ្រាមតស៊ូរបស់យើង ឲ្យពួកគាត់អាចចាកផុតពីរចនាសម្ព័ន្ធសង្គមចាស់និងដើម្បីលើកកម្ពស់បង្កបង្កើតផល។

*(រូបភាព)៖* **នៅក្នុងផលិតកម្មកសិកម្ម យើងបានពង្រីងនិងពង្រីកចលនាប្រវាស់ដៃយ៉ាងទូលំទូលាយ។ នៅ ដំបែ ដែលជាទីតាំងដ៏សំខាន់មួយរបស់ចលនាតស៊ូកម្ពុជា នារីៗកំពុងនាំគ្នាសាបព្រួសស្រូវ។**

ដីដែលជាកម្មសិទ្ធរបស់ពួកជនក្បត់ជាតិ សរុបរាប់ពាន់ហិកតារ ត្រូវបានរឹបអូសនិងត្រូវបានប្រែក្លាយទៅជាសម្បត្តិរួមរបស់អង្គការប្រជាជន ឬត្រូវបានបែងចែកឲ្យកសិករក្រីក្រដែលមិនមានដីធ្លីដោយយោងទៅតាមល័ក្ខខ័ណ្ឌជាក់ស្តែងនៅនឹងកន្លែង។

ដីដែលម្ចាស់មិននៅដោយសារមូលហេតុផ្សេងៗក្រៅពីអំពើក្បត់ជាតិនោះ ត្រូវបានប្រគល់ជូនអង្គការប្រជាជនទុកជាសម្បត្តិរួមដើម្បីឲ្យរដ្ឋយកទៅធ្វើស្រែចំការ ឬបើសិនជាចាំបាច់យកទៅបែងចែកឲ្យទៅកសិករក្រីក្រដែលគ្មានដីធ្លីសម្រាប់រយៈពេលកំណត់ណាមួយ ឬក៏ត្រូវបានជួលឲ្យពួកគេតែម្តង។ ផលមួយចំណែកដែលបានមកពីដីដែលរដ្ឋជាអ្នកធ្វើកសិកម្ម ត្រូវបានរក្សាទុកឲ្យម្ចាស់ដី តាមពិចារណាលើអាកប្បកិរិយាខាងនយោបាយរបស់ពួកគេចំពោះសង្គ្រាមតស៊ូដែលដឹកនាំដោយរណសិរ្សរួបរួមជាតិកម្ពុជា។

ដីទំនេរដែលម្ចាស់ធ្លាប់បានចូលរួមនៅក្នុងចលនាតស៊ូត្រូវបានធ្វើកសិកម្មដោយកសិករក្រីក្រដែលគ្មានដីដោយចំណាយថ្លៃឈ្នួលតែបន្តិចបន្តួចប៉ុណ្ណោះ។ ចំពោះដីដែលថ្មីសុទ្ធសាធដែលមិនមានម្ចាស់នោះ យើងបានប្រគល់ឲ្យកសិករក្រីក្រយកទៅដាំដុះ។

និយាយរួម ថ្លៃឈ្នួលដីដែលធ្លាប់តែលើសតម្លៃផលិតកម្មរហូតដល់ទៅ ៥០ភាគរយនោះ ត្រូវបានកាត់បន្ថយយ៉ាងច្រើន។ អត្រាការប្រាក់ដែលធ្លាប់តែលើសពី ៥០-៦០ភាគរយក្នុងមួយឆ្នាំនោះ ក៏ត្រូវបានហាមឃាត់។

ដើម្បីធ្វើឲ្យនយោបាយកសិកម្មដែលអនុលោមទៅតាមកម្មវិធីនយោបាយរបស់រណសិរ្ស រួបរួមជាតិកម្ពុជាទទួលបានផលល្អ យើងបានអនុវត្តសកម្មភាពដូចខាងក្រោមនេះ៖

- ការងារបំផុសបំផុលសកម្មភាពបង្កើនផលិតកម្មកសិកម្មទៅដល់កសិករ ទាំងអ្នកក្រ ទាំងអ្នកមាន ដើម្បីឲ្យពួកគេបានយល់ និងអនុវត្តគោលនយោបាយនោះឲ្យបានតឹងរឹងបំផុត។ អ្នកដែលអន្ទះសារចង់អនុវត្តគោលនយោបាយនោះខ្លាំងគឺពួកយុទ្ធជនដែលស្មោះស្ម័គ្រនៅក្នុងសង្គ្រាមដើម្បីរំដោះជាតិរបស់យើង។
- ការរៀបចំកសិករទាំងអស់ ដែលទទួលយកកំណែទម្រង់ខាងវិស័យកសិកម្មរបស់យើងទៅជាសមាគមកសិករស្នាហារជាតិ។

យើងបានលើកទឹកចិត្តដល់ការបង្កើតសហករណ៍អ្នកផលិត និងសហករណ៍អ្នកប្រើប្រាស់ផលិតផលដើម្បីលុបបំបាត់ឈ្មួញកណ្ដាល។ នៅក្នុងផលិតកម្មកសិកម្ម ចលនាប្រវាស់ដៃត្រូវបានពង្រីកយ៉ាងទូលំទូលាយក្នុងចំណោមប្រជាកសិករ។ នៅក្នុងគណៈកម្មាធិការនិមួយៗនៅគ្រប់ជាន់ថ្នាក់រដ្ឋបាលរបស់រណសិរ្សរួបរួមជាតិកម្ពុជា កម្មាភិបាលម្នាក់ត្រូវបានគេតែងតាំងឲ្យទទួលខុសត្រូវក្នុងការតាមដានការអភិវឌ្ឍនៃផលិតកម្មដែលមានគោលដៅចម្បងគឺ ផ្គត់ផ្គង់ដល់សង្គ្រាមតស៊ូរបស់យើង។ ស្របទៅតាមការអប់រំខាងផ្នែកនយោបាយ និងចលនាជួយគ្នាទៅវិញទៅមក កសិករទាំងឡាយបាន និងកំពុងព្យាយាមបង្កើនការធ្វើស្រែពីរដងក្នុងមួយឆ្នាំ។ ដោយគិតដល់សង្គ្រាមដែលអាចនឹងអូសបន្លាយយូរអង្វែងនោះ យើងក៏បានចាត់ទុកការដាំដុះដំណាំរួមផ្សំព្រមទាំងការចិញ្ចឹមជ្រូកនិងបសុបក្សីជាកត្តាមានសារៈសំខាន់។

**សំណួរទី ៥៖ សេដ្ឋកិច្ចនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួក លន់ នល់ សិរិមតៈ កំពុងតែជាប់គាំង។ ចុះចំណែកនៅក្នុងតំបន់រំដោះវិញ តើយ៉ាងដូចម្ដេចដែរ?**

ចម្លើយ៖ ដោយបានដឹងអំពីគម្រោងការណ៍របស់ពួកចក្រពត្តិនិយមអាមេរិក យើងបានបង្វែរកិច្ចខិតខំប្រឹងប្រែងរបស់យើងទៅរកការបង្កបង្កើនផល សម្រាប់បម្រើឲ្យការតស៊ូយូរអង្វែងវិញ។ ត្រង់ចំណុចនេះ វាជាការសំខាន់ដែលយើងត្រូវតែរក្សាជំហរនយោបាយឯករាជ្យ។

គួបផ្សំជាមួយនឹងកំណែទម្រង់បែបប្រជាធិបតេយ្យ ដែលត្រូវបានអនុវត្តរួចមកហើយ ដើម្បីលើកទឹកចិត្តប្រជាកសិករឲ្យខំប្រឹងប្រែងពង្រីកផលិតកម្មទៀតនោះ យើងបានដាក់ចេញនូវយុទ្ធនាការជំរុញការដាំដុះនៅគ្រប់ស្ថាប័នសេវាសាធារណៈ និងអង្គភាពកងទ័ពទាំងអស់ដើម្បីបំពេញតម្រូវការរបស់ប្រជាជនឲ្យបានគ្រប់គ្រាន់បំផុតតាមដែលយើងអាចធ្វើទៅបាន។

ក្រៅអំពីការដាំដុះបង្កបង្កើនផលឲ្យបានល្អ យើងក៏បានអភិវឌ្ឍសិប្បកម្មដើម្បីបម្រើដល់ប្រជាជននិងសង្គ្រាមតស៊ូរបស់យើងផងដែរ ដោយរួមទាំងសម្លៀកបំពាក់ ឧបករណ៍ធ្វើពីដីឧបករណ៍កសិកម្ម ក្រដាស់ សាប៊ូ និងប្រេងជាដើម។ គុណភាពផលិតផលទាំងនោះក៏ត្រូវបានបង្កើនជាលំដាប់ផងដែរ។

ពីដំបូង ការទម្លាក់គ្រាប់បែកនិងការបាចសារធាតុគីមីពីលើយន្តហោះឥតឈប់ឈរបានបង្កការរំខានយ៉ាងខ្លាំងដល់ប្រជាជនយើង។ ប៉ុន្តែ មិនយូរប៉ុន្មាន ពួកគាត់ចេះការពារខ្លួននិងវាលស្រែព្រមទាំងឧបករកសិកម្មរបស់ពួកគាត់បាន។ បើទោះបីជាជួបប្រទះការលំបាកដែលបង្កឡើងដោយការវាយឆ្មក់ពីលើអាកាសក៏ដោយ ប្រជាជនយើងនៅតែអាចបន្តធ្វើការងារលើដីស្រែចំការរបស់ពួកគាត់បានជាធម្មតា។

ដោយសារតែពួកគាត់មានសម្បជញ្ញៈនយោបាយខ្ពស់ និងមានការតាំងចិត្តខ្ពស់ក្នុងការដណ្តើមយកជ័យជំនះផងដែរនោះ ប្រជាជនយើងក៏បានសម្រេចក្នុងការបំពេញតម្រូវការរបស់ខ្លួននិងក្នុងការផ្គត់ផ្គង់ដល់សង្គ្រាមតស៊ូ។ នៅពេលដែលផលិតកម្មបានកើនឡើង យើងក៏បានបែងចែកជាវិភាគទានសម្រាប់ផ្គត់ផ្គង់ដល់សង្គ្រាមរំដោះជាតិ។ វិភាគទានទាំងនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការផ្តល់ផលប្រយោជន៍ទៅវិញទៅមកនៅក្នុងគ្រប់ផ្នែកនៃសង្គម និងអង្គការតស៊ូនានាដែលតែងតែគិតគូរដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដោយយោងទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ប្រជាជនម្នាក់ៗ និងយោងទៅតាមកម្រិតនៃសម្បជញ្ញៈនយោបាយរបស់ពួកគេ។ ទាំងនេះសុទ្ធតែចេញមកពីវិស័យពាណិជ្ជកម្ម កសិកម្ម និងឧស្សាហកម្ម។ និយាយជារួម គឺថាវាត្រូវបានកាត់បន្ថយឬមួយត្រូវបានលុបបំបាត់ចោលតែម្តង។

តម្លៃទំនិញត្រូវបានកំណត់ទៅតាមគោលការណ៍ ដែលអនុញ្ញាតឲ្យការធ្វើជំនួញលក់ដូរអាចផ្តល់ប្រយោជន៍ដល់ប្រជាជន ចលនាតស៊ូ និងពាណិជ្ជករដែលមិនយកចំណេញហួសហេតុពីអ្នកដទៃ។ ដើម្បីសម្រួលដល់ការគ្រប់គ្រងតម្លៃ យើងបាននិងកំពុងតែពង្រីកបណ្តាញផ្គត់ផ្គង់និងរកទីផ្សារសំរាប់សហករណ៍។ វិធានការទាំងនេះបានផ្តល់លទ្ធភាពដល់ការធ្វើឲ្យមានលំនឹងនៃតម្លៃទំនិញប្រើប្រាស់ប្រចាំថ្ងៃ។ ដូច្នេះ សាច់ជ្រូកមួយគីឡូក្រាមថ្លៃត្រឹមតែ ២០រៀលប៉ុណ្ណោះខណៈពេលដែលនៅភ្នំពេញថ្លៃជាង ២០០រៀល។

យើងក៏បានបណ្តុះគំនិតសន្សំសំចៃនៅក្នុងស្ថានប័នសេវាសាធារណៈ អង្គភាពតស៊ូ និងប្រជាជនយើងផងដែរ ដូចជាឲ្យចេះសន្សំប្រាក់ សំរាប់ទិញរបស់របរចាំបាច់ផ្សេងៗ ដូចជាសម្លៀកបំពាក់ ម្ហូបអាហារ និងថ្នាំសង្កូវ ជាដើមក្រោមមាគ៌ា “ខ្លួនទីពឹងខ្លួន”។

**សំណួរទី ៦៖ តើលោកបានសម្រេចសមិទ្ធិផលផ្សេងៗនៅក្នុងវិស័យវប្បធម៌ដែរឬទេ? ទាក់ទិននឹងបញ្ហានេះ តើលោកបានទទួលការរំខាន និងរារាំងពីសំណាក់ការវាយឆ្មក់តាមអាកាសរបស់អាមេរិកច្រើនដែរឬទេ? តើគោលជំហរខេមរយានកម្មនៅក្នុងវិស័យអប់រំមានដល់កម្រិតណាដែររហូតមកដល់ពេលនេះ?**

*(រូបភាព)៖* **បើទោះបីជាមានការទម្លាក់គ្រាប់បែកនិងវាយឆ្មក់តាមអាកាសពីសំណាក់ពួកអាមេរិកនិងបរិវារយ៉ាងណាក៏ដោយ ក៏យើងនៅតែមានលទ្ធភាពសម្របសម្រួលវិស័យអប់រំរបស់យើងទៅតាមស្ថានភាពមានសង្គ្រាមនោះដែរ។ កុមារទាំងអស់សុទ្ធតែបានទទួលការពន្យល់ណែនាំនិងបង្ហាត់បង្រៀន។**

ចម្លើយ៖ នៅទូទាំងតំបន់រំដោះទាំងមូល ការអប់រំត្រូវបានផ្តល់ដោយឥតគិតថ្លៃ។ ថ្នាក់អក្ខរកម្មត្រូវបានដំណើរការគ្រប់ទីកន្លែង។ តាមការពិត ការវាយឆ្មក់របស់ខ្មាំងពិតជាបានបង្កការរំខានដល់ការអប់រំកុមារយ៉ាងខ្លាំងមែន។ ពួកឈ្លានពានចក្រពត្តិនិយមអាមេរិក បក្សពួករបស់គេនៅសៃហ្គន និងក្រុមជនក្បត់ជាតិ លន់ នល់ សិរិមតៈ សឺន ង៉ុកថាញ់ សុទ្ធតែសាហាវព្រៃផ្សៃជាទីបំផុត។ ពួកគេបានលុបបំបាត់អ្វីៗទាំងអស់ដោយការទម្លាក់គ្រាប់បែក រាប់តាំងពីសាលារៀន វិទ្យាល័យ មន្ទីរពេទ្យ និងវត្តអារាមជាដើម។ ទោះបីជាយ៉ាងនេះក៏ដោយ យើងនៅតែមានលទ្ធភាពសម្របសម្រួលវិស័យអប់រំរបស់យើងទៅតាមស្ថានភាពមានសង្គ្រាមនោះដែរ ដោយមានលក្ខណៈ

ជាវិស័យអប់រំដែលពឹងផ្អែកទៅលើសេដ្ឋកិច្ចនយោបាយ វេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រយោធា។ យើងក៏បានគិតគូរដល់ការបង្ហាត់បង្រៀនអំពីសិល្បៈនិងវប្បធម៌ផងដែរ។ ការបង្ហាត់បង្រៀននេះត្រូវបានធ្វើឡើងជាភាសាខ្មែរទាំងស្រុង។ ការអប់រំដែលគ្មានឥទ្ធិពលពីខាងក្រៅដែលនាំឲ្យវិនាសអន្តរាយផ្សេងៗ ការអប់រំនេះបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធរវាងទ្រឹស្តីនិងការអនុវត្តនៅក្នុងលក្ខខណ្ឌពិសេសនៃស្ថានភាពប្រទេសជាតិ។ យើងបានបានខិតខំធ្វើឲ្យសមស្របទៅតាមតម្រូវការដ៏ជាក់លាក់របស់ប្រទេសជាតិនាពេលបច្ចុប្បន្ន។

*(រូបភាព)៖* **យើងក៏បានគិតគូរដល់ការបង្ហាត់បង្រៀនអំពីសិល្បៈនិងវប្បធម៌ផងដែរ។**

**សំណួរទី ៧៖ តើអង្គភាពពេទ្យរបស់លោកអាចបំពេញតម្រូវការរបស់ប្រជាជននិងសង្គ្រាមបានដែរឬទេ?**

ចម្លើយ៖ និយាយជាទូទៅ អង្គភាពពេទ្យរបស់យើងអាចបំពេញតម្រូវការរបស់ប្រជាជននិងសង្គ្រាមបាន។ ឱសថដែលយើងប្រើប្រាស់ត្រូវបានផលិតឡើងពីសារធាតុផ្សំសាមញ្ញៗ ហើយវាបានបង្ហាញថាមានភាពស័ក្តិសិទ្ធិក្នុងការព្យាបាលតាមបែបបុរាណ។ យើងបានបណ្តុះបណ្តាលគិលានុបដ្ឋាកនិងឆ្មបប្រុសៗ ដោយភាគច្រើននៃអ្នកទាំងនោះជាអ្នកជនបទក្រីក្រហើយថែមទាំងមិនចេះអក្សរទៀតផង។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេលបីឆ្នាំ ដោយក្នុងមួយឆ្នាំៗ គេត្រូវរៀនទ្រឹស្តី ៣ខែនិងរៀនអនុវត្តន៍ ៩ខែ។ បុគ្គលិកពេទ្យមានរួមបញ្ចូលស្ត្រីជាច្រើន។ នៅក្នុងការរៀបចំក្រុមអ្នកជំនាញខាងពេទ្យសម្រាប់កងទ័ពជាតិរំដោះប្រជាជនកម្ពុជាវិញ យើងមានគិលានុបដ្ឋាកពីរនាក់ក្នុងភូមិនីមួយៗ គណៈកម្មការពេទ្យមួយក្នុងឃុំនីមួយៗ វេជ្ជបណ្ឌិតមួយរូបក្នុងស្រុកនីមួយៗ និងមន្ទីរពេទ្យមួយ ឬពីរបីក្នុងខេត្តនីមួយៗ។

*(រូបភាព)៖* **មន្ទីរពេទ្យខេត្តស្ទឹងត្រែងបណ្តុះបណ្តាលគិលានុបដ្ឋាក និងគិលានុបដ្ឋាយិកានៅនឹងកន្លែង ។ រូបនេះបង្ហាញសកម្មភាពហាត់រុំរបួសជាមួយនឹងឈើអបឆ្អឹង។**

**សំណួរទី ៨៖ តើវត្តមានរួមគ្នានៃលោកសង្ឃព្រះពុទ្ធសាសនា និងពួកយុទ្ធជនដែលមានកំពុងរីកធំនិងម៉ាក្សនិយមនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជានោះបានធ្វើឱ្យមានបញ្ហាធ្ងន់ធ្ងរកើតឡើងដែរឬទេ?**

ចម្លើយ៖ ប្រវត្តិសាស្ត្រកម្ពុជាក្នុងរយៈពេលប៉ុន្មានរយឆ្នាំចុងក្រោយនេះគឺពោរពេញទៅដោយវីរភាពដ៏គួរឱ្យកោតសរសើរ ប្រឆាំងនឹងការគ្រប់របស់ពួកអាណានិគមនិយម ជាពិសេសគឺពួក "អាចារ្យ" ដែលជាអតីតលោកសង្ឃព្រះពុទ្ធសាសនានេះឯង។ តាំងពីយូរលង់ណាស់មកហើយមានតែពួកគេទាំងនេះទេ ដែលជាអ្នកបានរៀនសូត្រចេះដឹងនិងមានឥទ្ធិពលខ្លាំងលើមនុស្សម្នាជាច្រើន ដែលជាហេតុធ្វើពួកគេបានរួមចំណែកជួយយ៉ាងច្រើនដល់កិច្ចការថែរក្សាសម្បត្តិវប្បធម៌និងប្រពៃណីជាតិឱ្យចៀសផុតពីការទទួលរងឥទ្ធិពលអាក្រក់ទាំងឡាយពីបរទេស។ នាពេលបច្ចុប្បន្ននេះ នៅក្នុងសង្គ្រាមបដិវត្តន៍ដើម្បីរំដោះប្រជាជន និងប្រទេសជាតិរបស់យើង ពួកគេកំពុងតែចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងការចលនាកម្លាំងស្នេហាជាតិ។ ពួកគេគឺជាសាក្សីដែលបានឃើញដោយផ្ទាល់ភ្នែក និងជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងរបស់ពួកឈ្លានពានអាមេរិកនិងបរិវារដែលបានបំផ្លិចបំផ្លាញវត្តអារាម សម្លាប់មនុស្សជាទីស្រឡាញ់របស់ពួកគេ និងបង្ខំឱ្យពួកគេធ្វើសកម្មភាពដែលសាសនាហាមឃាត់។

*(រូបភាព)៖* **នៅក្នុងខេត្តក្រចេះដែលត្រូវបានរំដោះ ព្រះសង្ឃព្រះពុទ្ធសាសនានិងប្រជាជនប្រារព្ធពិធីជូនដំណើរយុទ្ធជនដែលត្រូវចាកចេញទៅសមរភូមិមុខ។**

ពួកគេបានបែងចែកយ៉ាងច្បាស់រវាងមិត្តនិងខ្មាំង និងរវាងអ្នកស្នេហាជាតិនិងជនក្បត់ជាតិ។ មាគ៌ានយោបាយដ៏ច្បាស់លាស់និងត្រឹមត្រូវរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលឈរលើមូលដ្ឋានសាមគ្គីភាពដ៏ទូលំទូលាយបំផុតរបស់កងកម្លាំងស្នេហាជាតិ ដោយមិនគិតអំពីនិន្នាការនយោបាយ ភេទ និងជំនឿនោះ មិនបានធ្វើឱ្យមានទំនាស់រវាងព្រះសង្ឃព្រះពុទ្ធសាសនានិងកងកម្លាំងដទៃទៀតដែលកំពុងតស៊ូច្បាំងដើម្បីរំដោះជាតិនោះឡើយ។ ជាមួយនឹងប្រពៃណីតស៊ូរបស់ពួកគេ បព្វជិតព្រះពុទ្ធសាសនានៅទូទាំងកម្ពុជាក៏មានគំនិតដូចសមាជិករបស់រណសិរ្សរួបរួមជាតិកម្ពុជាដែរ នៅក្នុងការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់ពួកចក្រពត្តិនិយមអាមេរិកនិងបរិវារ។

គ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា ទាំងនៅតំបន់រំដោះនិងតំបន់ដែលស្ថិតក្រោមការកាន់កាប់របស់ខ្មាំងជាបណ្តោះអាសន្ន ព្រះសង្ឃព្រះពុទ្ធសាសនាបានតស៊ូប្រយុទ្ធយ៉ាងស្វិតស្វាញដោយមានទឹកចិត្តស្នេហាជាតិដែលកំពុងតែពុះកញ្ជ្រោល។ គោលនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាគឺគោរពសិទ្ធិនិងសេរីភាពរបស់ព្រះសង្ឃដែលស្មោះត្រង់និងភក្តីចំពោះរណសិរ្សរួបរួមជាតិកម្ពុជានិងប្រជាជនកម្ពុជា។

ដូច្នេះ ទាំងនៅក្នុងចលនាតស៊ូពីអតីតកាលនិងនៅក្នុងសង្គ្រាមបដិវត្តន៍ដើម្បីរំដោះប្រជាជននិងប្រទេសជាតិនាពេលបច្ចុប្បន្ន គេឃើញមានភាពដូចគ្នាយ៉ាងខ្លាំងនៃទស្សនៈនិងសកម្មភាពរបស់ព្រះសង្ឃ ភាពជឿនលឿន និងបដិវត្តន៍។ យើងជឿជាក់ថាសាមគ្គីភាពនេះនឹងមិនត្រឹមតែត្រូវបានថែរក្សាឲ្យនៅគង់វង្សប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងត្រូវបានពង្រឹងនិងអភិវឌ្ឍនៅក្នុងពេលអនាគតដើម្បីបុព្វហេតុបដិវត្តន៍នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីរំដោះជាតិមាតុភូមិនោះផងដែរ។

**សំណួរទី ៩៖ ពិភពលោកបានដឹងយ៉ាងច្បាស់អំពីបុគ្គលិកលក្ខណៈរបស់សម្តេច នរោត្តម សីហនុ ប៉ុន្តែមិនសូវដឹងច្រើនប៉ុន្មានទេអំពីពួកមេដឹកនាំនៅក្នុងប្រទេសរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ សូមលោកមេត្តាជួយរៀបរាប់ប្រាប់យើងខ្ញុំជាពិសេសអំពីលោក ខៀវ សំផន ដែលជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីការពារជាតិ ផងបានទេ?**

ចម្លើយ៖ មេដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានៅក្នុងប្រទេសទាំងអស់សុទ្ធតែជាយុទ្ធជននិងជាបដិវត្តន៍ដែលមានជំហររឹងឆ្វាយ។ ដោយសារតែស្មារតីប្រុងប្រយ័ត្នខ្ពស់របស់ខ្លួន ពួកគេអាចគេចផុតពីការបង្ក្រាបដ៏សាហាវឃោរឃៅរបស់ពួកចក្រពត្តិអាមេរិកនិងក្រុម លន់ នល់ សិរិមតៈ សឺន ង៉ុកថាញ់។ ពួកគេធ្លាប់មានបទពិសោធន៍នៅក្នុងសង្គ្រាមប្រឆាំងនឹងអាណានិគមនិយមបារាំង (១៩៥១-១៩៥៤) នៅក្នុងសកម្មភាពនយោបាយប្រឆាំងនឹងពួកចក្រពត្តិនិយមអាមេរិក (១៩៥៥-១៩៧០) និងនៅក្នុងចលនាតស៊ូនយោបាយនិងប្រដាប់អាវុធប្រឆាំងនឹងការឈ្លានពានរបស់អាមេរិកពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧០ រហូតមក។

នៅក្នុងការប្រាស្រ័យទាក់ទងជាមួយក្រុមមហាជន ពួកគេឥឡូវនេះអាចបង្កើតបានជាការដឹកនាំជាសមូហភាពស្របទៅតាមមាគ៌ានយោបាយដែលត្រូវបានកំណត់ដោយរណសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្តេច នរោត្តម សីហនុ ដែលជាប្រមុខរដ្ឋ ជាព្រះប្រធាន និងសម្តេច ប៉ែន នុត ជាប្រធានការិយាល័យនយោបាយរបស់រណសិរ្សនេះ។

លោក ខៀវ សំផន ដែលទទួលបានសញ្ញាប័ត្របណ្ឌិតសេដ្ឋកិច្ចមកពីសាកលវិទ្យាល័យប៉ារីសនោះ បានចូលរួមក្នុងសកម្មភាពស្នេហាជាតិតាំងពីយូរមកហើយ។ តាំងពីឆ្នាំ ១៩៤៦ មក លោកបានចូលរួមយ៉ាងសកម្មនៅក្នុងចលនាសិស្សនិស្សិតនៅកម្ពុជាដើម្បីបុព្វហេតុឯករាជ្យជាតិប្រឆាំងនិងអាណានិគមនិយមបារាំង។

*(រូបភាព)៖* **ការប្រជុំគណៈរដ្ឋមន្ត្រីនៅតំបន់រំដោះរបស់កម្ពុជា។ រូបខាងមុខ គឺលោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី នៅខាងស្តាំគឺ លោក ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មាននិងឃោសនាការ។ រូបខាងឆ្វេងគឺលោក ប៉ុក ដឺ កុមារ (Poc Doeus Komar) អនុរដ្ឋមន្ត្រីការបរទេស។ រូបពីក្រោយខាងឆ្វេងគឺលោក ទីវ អុល អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាននិងឃោសនាការ និងខាងស្តាំគឺលោក ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កំណែទម្រង់សហគមន៍ និងសហប្រតិបត្តិការ។**

បន្ទាប់ពីទៅដល់ប្រទេសបារាំងនៅឆ្នាំ ១៩៥៣ លោកបានចូលរួមយ៉ាងប្តូរផ្តាច់នៅក្នុងការប្រយុទ្ធរបស់ប្រជាជនបារាំងប្រឆាំងនឹងសង្គ្រាមអាណានិគមនៅឥណ្ឌូចិន។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ នៅឆ្នាំ ១៩៥៤ នោះមក លោកបានដឹកនាំចលនាតស៊ូរបស់ប្រជាជននិងនិស្សិតខ្មែរប្រឆាំងនឹងពួកចក្រពត្តិនិយមអាមេរិក និងបរិវារនៅក្នុងប្រទេសកម្ពុជា។ នៅពេលត្រឡប់មកដល់ស្រុកកំណើតវិញនៅឆ្នាំ ១៩៥៨ លោកបានបន្តសកម្មភាពស្នេហាជាតិក្រោមរូបភាពផ្សេងៗដូចជា៖ ក្នុងការសែតរបស់លោកឈ្មោះថា "អ្នកសង្កេតការណ៍" ដែលលោកជាចាងហ្វាង នៅលើវេទិកាសមាជជាតិ និងនៅសភាជាតិក្នុងឋានៈជាអនុប្រធានរយៈពេលពីអាណត្តិ (១៩៦២-១៩៦៦ និង ១៩៦៦-១៩៧០) ជាដើម។ ដោយសារតែគាត់មានភាពក្លាហាននិងសមានចិត្តចំពោះមហាជនជាទូទៅនោះ ប៉ូលីសបានតាមដានលោកជាប់ជានិច្ច ហើយត្រូវប្រឈមនឹងការរករឿង សម្លុតគម្រាមកំហែង និងធ្វើទុក្ខបុកម្នេញជាច្រើនផង... ដែលគេចោទប្រកាន់ថាជា

ជនក្បត់ជាតិហ្វាស៊ីសនិយម ដែលនាំឲ្យគាត់ជាប់ពន្ធនាគារអស់រយៈពេលជាច្រើនខែនៅឆ្នាំ ១៩៦០ នោះ ពួកគេបានប៉ុនប៉ងសម្លាប់លោកជាច្រើនដង ហើយនៅឆ្នាំ ១៩៦៧ ពួកគេបានកោះហៅលោកឲ្យចូលខ្លួននៅតុលាការយោធាជាមួយលោក ហ៊ូ យន់ និង ហ៊ូ នឹម បើទោះបីជាពួកគាត់ទាំងអស់គ្នាសុទ្ធតែជាតំណាងរាស្ត្រដែលត្រូវបានប្រជាជនបោះឆ្នោតជូនដោយស្របច្បាប់ និងជាអនុប្រធានសភាជាតិក៏ដោយ។ ដើម្បីចៀសវាងផែនការដែលញុះញង់ដោយពួក សេ.អ៊ី.អា ដែលស្រដៀងគ្នានេះដែរ របស់ក្រុមជនក្បត់ជាតិ លន់ ណល់ សិរិមតៈ សឺន ង៉ុកថាញ់ នោះ លោក ខៀវ សំផន និងអ្នកស្នេហាជាតិផ្សេងទៀតជាច្រើនដូចជាលោក ហ៊ូ យន់ និង ហ៊ូ នឹម ត្រូវបង្ខំចិត្តរត់ចូលព្រៃម៉ាគី នៅឆ្នាំ ១៩៦៧ ដើម្បីបន្តការតស៊ូប្រយុទ្ធជាមួយប្រជាជន។ តាំងពីពេលនោះមក ជីវិតរបស់លោក ខៀវ សំផន តែងតែពោរពេញទៅដោយសកម្មភាពបដិវត្តន៍ដ៏មមាញឹកជាទីបំផុត និងជួបប្រទះនូវការលំបាកនិងឧបសគ្គជាច្រើនទៀតផង។

ដោយសារតែចំណេះដឹងដ៏ទូលំទូលាយរបស់លោក និងជាពិសេសកេរ្តិ៍ឈ្មោះរបស់លោកនៅក្នុងប្រទេសកម្ពុជានិងនៅក្រៅប្រទេស ក្នុងចំណោមប្រជាជននៅជនបទព្រមទាំងអ្នកក្រុង (កម្មករ និយោជិត សិស្សនិស្សិត បញ្ញវន្ត ភិក្ខុសង្ឃ មន្ត្រីរាជការ ទាហាន និងពាណិជ្ជករថ្នាក់មធ្យម) ក្នុងសភាជាតិនិងរដ្ឋាភិបាល ក្នុងការងារស្របច្បាប់និងការងារសម្ងាត់របស់លោក និងក្នុងសកម្មភាពយោធានិងនយោបាយអស់រយៈពេលជាងពីរទសវត្សរ៍របស់លោកប្រឆាំងនឹងពួកអាណានិគមនិយមបារាំង និងពួកចក្រពត្តិនិយមអាមេរិកនិងបរិវារនោះ លោក ខៀវ សំផន ក៏បានក្លាយជាអ្នកស្នេហាជាតិដ៏លេចធ្លោមួយរូប ដែលពោរពេញទៅដោយបទពិសោធន៍ខាងបដិវត្តន៍និងមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ដឹកនាំសង្គ្រាមបដិវត្តន៍ដើម្បីរំដោះជាតិរបស់យើងរហូតទាល់តែបានជោគជ័យទាំងស្រុង។ ការបូជារបស់លោកចំពោះចលនាដើម្បីឯករាជ្យជាតិ សេរីភាព និងប្រជាធិបតេយ្យ បានក្លាយជាគំរូដ៏រស់រវើកសម្រាប់ប្រជាជននិងយុទ្ធជនរបស់យើងក្នុងនាមជាអ្នកស្នេហាជាតិដ៏ពិតប្រាកដនិងលេចធ្លោ។

**សំណួរទី ១០៖ អ្វីទៅជាទស្សនៈវិស័យ សម្រាប់រយៈពេលខ្លីនិងសម្រាប់រយៈពេលវែង នៃសង្គ្រាមតស៊ូនៅកម្ពុជា?**

ចម្លើយ៖ ដោយចាប់ផ្តើមនៅឆ្នាំ ១៩៧២ ប្រជាជនយើងនិងកងកម្លាំងប្រដាប់អាវុធរបស់ពួកគេ បានបើកការវាយប្រហារដ៏ប្រកបដោយជោគជ័យខ្ពស់ជាច្រើនលើក។ ការធ្វើខ្មែរូបនីយកម្មរបស់សហរដ្ឋអាមេរិកបានទទួលបរាជ័យទាំងស្រុង។ តែទោះយ៉ាងណា គេរំពឹងថាសង្គ្រាមធំៗជាងនេះអាចនឹងកើតមានទៀតនៅឆ្នាំនេះ។

**កម្ពុជា**

**សកម្មភាពនៅខែឧសភា ឆ្នាំ ១៩៧២ នៃការរំដោះកម្ពុជា**

**ដោយកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា**

*(ផែនទីប្រទេសកម្ពុជា)*

តំបន់រំដោះទាំងស្រុង *(ចំណាំពីក្រោមផែនទីខាងឆ្វេង)*

តំបន់រំដោះបានខ្លះនិងចលនាឧទ្ទាម *(ចំណាំពីក្រោមផែនទីខាងស្តាំ)*